**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤១ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល



www.pheakdeylaw.com

## សម្រេច

**ប្រការ១ ._**

ត្រូវបានផ្លាស់ប្ដូរ សមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅតាមបណ្ដារាជធានី ខេត្ត ដូចខាងក្រោម ៖

| | |
|---|---|
| ១-ឯកឧត្តម អ៊ុក ប្រាថ្នា | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន ពីអនុប្រធានក្រុមការងារខេត្តរតនគិរី មកជាសមាជិកក្រុមការងាររាជធានីភ្នំពេញ។ |
| ២-លោកជំទាវ ដាំ ដារីនី | រដ្ឋលេខាធិការក្រសួងការពារជាតិ ពីសមាជិកក្រុមការងារខេត្តកំពង់ស្ពឺមកជាសមាជិកក្រុមការងារខេត្តត្បូងឃ្មុំ |
| ៣-លោកជំទាវ ប៉ែន ឆដា | រដ្ឋលេខាធិការក្រសួង រ៉ែ និងថាមពល ពីសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ មកជាសមាជិកក្រុមការងារខេត្តពោធិ៍សាត់ |
| ៤-ឯកឧត្តម ម៉ម វណ្ណៈ | រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ពីសមាជិកក្រុមការងារខេត្តព្រះសីហនុ មកជាសមាជិកក្រុមការងារខេត្តកណ្ដាល |
| ៥-លោកជំទាវ ច័ន្ទ ធី | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន ពីសមាជិកក្រុមការងារខេត្តស្វាយរៀង មកជាសមាជិកក្រុមការងារខេត្តតាកែវ |
| ៦-លោកជំទាវ សម មុន្នីកា | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ពីសមាជិកក្រុមការងារ ខេត្តពោធិ៍សាត់ មកជាសមាជិកក្រុមការងារខេត្តកំពង់ធំ |
| ៧-លោកជំទាវ កុយ សុដានី | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម ពីសមាជិកក្រុមការងារខេត្តស្ទឹងត្រែង មកជាសមាជិកក្រុមការងាររាជធានីភ្នំពេញ |
| ៨-ឯកឧត្តម សរ សុពុត្រា | អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ពីសមាជិកក្រុមការងារខេត្តស្វាយរៀង មកជាសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ |
| ៩-លោកជំទាវ ទិត លីនដា | អនុរដ្ឋលេខាធិការក្រសួង រ៉ែ និងថាមពល ពីសមាជិកក្រុមការងាររាជធានីភ្នំពេញ មកជាសមាជិកក្រុមការងារខេត្តពោធិ៍សាត់ |
| ១០-ឯកឧត្តម ញ៉ឹក សុមេធ | អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល ពីសមាជិកក្រុមការងារខេត្តកំពង់-ឆ្នាំង មកជាសមាជិកក្រុមការងារខេត្តពោធិ៍សាត់ |
| ១១-ឯកឧត្តម ផែង សុវិជ្ជានោ | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ពីសមាកជិកក្រុមការងារខេត្តឧត្តរមានជ័យ មកជាសមាជិកក្រុមការងារខេត្តកំពង់ឆ្នាំង |
| ១២-ឯកឧត្តម ឈឹម សៅគី | អនុរដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី ពីសមាជិកក្រុមការងារខេត្តប៉ៃលិន មកជាសមាជិកក្រុមការងារខេត្តតាកែវ |



www.pheakdeylaw.com

| | |
|---|---|
| ១៣-ឯកឧត្តម អ៊ុន ទឹម | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ពីសមាជិកក្រុមការងារខេត្តកំពង់ចាម មកជាសមាជិកក្រុមការងារខេត្តកំពង់ស្ពឺ |
| ១៤-ឯកឧត្តម ខឹមវិសិដ្ឋ | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ពីសមាជិកក្រុមការងារខេត្តឧត្តរមានជ័យ មកជាសមាជិកក្រុមការងារខេត្តតាកែវ |
| ១៥-ឯកឧត្តម សាត សមុទ្រ | អនុរដ្ឋលេខាធិការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ពីសមាជិកក្រុមការងារខេត្តបាត់ដំបង មកជាសមាជិកក្រុមការងារខេត្តព្រៃវែង |

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលរាជធានី ខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*


www.pheakdeylaw.com